## តើខ្ញុំអាចប្រើឈាមរបស់ខ្ញុំផ្ទាល់បានឬទេ?

អ្នកខ្លះយល់ថា វាមានសន្តិសុខជាងក្នុងការប្រើឈាមរបស់គេផ្ទាល់ ប្រសិនបើត្រូវការនៅពេលវះកាត់។ ឈាមដែលគេបានចាក់យកមុនពេលវះកាត់ ហើយតម្កល់ទុកសំរាប់ការប្រើរបស់លោកអ្នកត្រូវបានគេហៅថាឈាមរបស់បុគ្គលដដែល។

ការនេះមិនអាចធ្វើបានគ្រប់តែពេល សំរាប់អ្នកជម្ងឺជាច្រើននោះឡើយ ហើយវេជ្ជបណ្ឌិតរបស់លោកអ្នកអាចពិភាក្សាអំពីសភាពគ្រោះថ្នាក់ និងផលប្រយោជន៍ទាំងឡាយដែលទាក់ទិននឹងរឿងនោះ មុនពេលវះកាត់របស់លោកអ្នក។

## បញ្ជីផ្ទៀងផ្ទាត់

- តើលោកអ្នកយល់ឬទេ ថាហេតុអ្វីបានជាលោកអ្នកអាចនឹងត្រូវការចាក់បញ្ចូលឈាម?
- តើលោកអ្នកត្រូវបានគេពន្យល់ប្រាប់ អំពីសភាពគ្រោះថ្នាក់ និងផលប្រយោជន៍ទាំងឡាយពីការចាក់បញ្ចូលឈាមហើយឬនៅ?
- តើលោកអ្នកយល់អំពីជំរើសផ្សេងទៀតក្រៅពីការចាក់បញ្ចូលឈាមឬទេ?
- តើគេបានឆ្លើយគ្រប់សំណួរទាំងឡាយរបស់លោកអ្នកហើយឬនៅ?

## សូមចងចាំ

ការចាក់បញ្ចូលឈាមត្រូវបានផ្តល់ជូនលោកអ្នកប៉ុណ្ណោះ ពេលណាផលប្រយោជន៍មានច្រើនជាងសភាពគ្រោះថ្នាក់សំរាប់លោកអ្នក។

លោកអ្នកត្រូវបានលើកទឹកចិត្តឲ្យសួរសំណួរទាំងឡាយអំពីការព្យាបាលរបស់លោកអ្នកនៅពេលណាក៏បាន។

ដើម្បីទទួលយកពត៌មានបន្ថែមទៀត:

www.nhmrc.gov.au

www.asbt.org.au

www.giveblood.redcross.org.au

## ការទាក់ទង

ដើម្បីទទួលយកពត៌មានបន្ថែមទៀត
សូមទាក់ទងជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក

## កិច្ចបំរើអ្នកបកប្រែភាសា

ប្រសិនបើលោកអ្នកមានបញ្ហាលំបាកជាមួយនឹងភាសាអង់គ្លេស លោកអ្នកអាចស្នើសុំអ្នកបកប្រែភាសាដែលមានវិជ្ជាជីវៈឲ្យជួយលោកអ្នកនៅក្នុងចម្ងល់ណាមួយដែលលោកអ្នកមាន អំពីពត៌មានដែលផ្តល់នេះ។ សូមស្នើសុំបុគ្គលិកឲ្យរៀបចំអ្នកបកប្រែភាសាជូនលោកអ្នក។

Cambodian

# ការណែនាំរបស់លោកអ្នក ទៅនឹងការចាក់បញ្ចូលឈាម

(Your Guide to Blood Transfusion)

សុខភាពប៉ែកខាងកើត វិចតូរីយ៉ា ឆ្នាំ២០០៥
សម្ភារៈនេះស្ថិតនៅក្រោមច្បាប់រក្សាសិទ្ធិ
ក៏ប៉ុន្តែអាចយកទៅប្រើ / ផលិតឡើងវិញទាំងមូល
ឬផ្នែកខ្លះ សំរាប់គោលបំណងមិនរកផលចំណេញ។

# ការចាក់បញ្ចូលឈាម

### តើវាជាអ្វី?

### តើហេតុអ្វីបានជាខ្ញុំត្រូវការវា?

លោកអ្នកបានទទួលសន្លឹកពត៌មាននេះ ដោយព្រោះតែវេជ្ជបណ្ឌិតរបស់លោកអ្នកពិចារណាឃើញថា លោកអ្នកអាចត្រូវការចាក់បញ្ចូលឈាម។

ការចាក់បញ្ចូលឈាមទាក់ទិននឹងការទទួលយកឈាម ឬផលិតផលដែលមកអំពីឈាម ចាក់បញ្ចូលទៅក្នុងរូបកាយរបស់លោកអ្នក។

គេត្រូវការចាក់បញ្ចូលឈាមសំរាប់មូលហេតុផ្សេងៗ។

### កោសិកាឈាមក្រហម

- ប្រើសំរាប់ព្យាបាលភាពមានឈាមមិនគ្រប់គ្រាន់ (ឈាមតិច)
- ប្រើក្នុងពេលវះកាត់ ឬក្រោយពីមានគ្រោះថ្នាក់ដើម្បីព្យាបាលការហូរចេញឈាមច្រើន។

### ផលិតផលឈាមឯទៀត

- ប្រើដើម្បីបញ្ឈប់ការហូរចេញឈាមដែលបណ្តាលមកពីថ្នាំព្យាបាល ការព្យាបាល ឬជម្ងឺជាក់លាក់ជាមួយ
- ប្រើដើម្បីដាក់ជំនួសឡើងវិញនូវកត្តាដែលនាំឲ្យឈាមកកជាក់លាក់ ឬប្រូតេអ៊ីនដែលជួយទប់ទល់ការហូរចេញឈាម។

### តើឈាមមកពីកន្លែងណាខ្លះ?

ឈាមទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី បានមកអំពីអ្នកធ្វើបរិច្ចាកឈាមស្ម័គ្រចិត្តដែលមិនបានទទួលប្រាក់។

### តើមានសភាពគ្រោះថ្នាក់ និងផលប្រយោជន៍ទាំងឡាយណាខ្លះកើតមានពីការចាក់បញ្ចូលឈាម?

**ផលប្រយោជន៍:** ឈាមអាចសង្គ្រោះជីវិត វាក៏អាចធ្វើឲ្យប្រសើរទៅដល់នូវគុណភាពនៃជីវិត សំរាប់អស់អ្នកដែលមានជម្ងឺឈាមជាក់លាក់ផងដែរ។

**សភាពគ្រោះថ្នាក់:** ការចាក់បញ្ចូលឈាម ដូចគ្នានឹងគ្រប់ទាំងការព្យាបាលផ្នែកពេទ្យ ទាក់ទិននឹងគ្រោះថ្នាក់ខ្លះ។

- ការឆ្លងជម្ងឺ - គ្រប់ទាំងឈាមត្រូវបានគេធ្វើតេស្តសំរាប់វ៉ាយរ៉ុស ដូចជាជម្ងឺហេប៉ាទីត (Hepatitis) ឬមេរោគអេដស៍ - ដូច្នេះគ្រោះថ្នាក់កើតមានពីការឆ្លងជម្ងឺគឺមានតិចជាទីបំផុត។ អ្នកធ្វើបរិច្ចាកឈាមដែលបានជាប់ទាក់ទិននឹងសភាពគ្រោះថ្នាក់ដល់ការផ្គត់ផ្គង់ឈាម (ដូចជាជម្ងឺបណ្តាលមកពីបាក់តេរី) មិនបានអនុញ្ញាតឲ្យបរិច្ចាកឈាមទេ។
- ប្រតិកម្ម - ប្រតិកម្មបន្តិចបន្តួចដូចជាគ្រុន ឬរមាស់ស្បែកអាចកើតមានឡើង។ លោកអ្នកនឹងត្រូវបានគេឃ្លាំមើលយ៉ាងជិតដិត ពេញទូទាំងការចាក់បញ្ចូលឈាម ដើម្បីឃ្លាំមើលសញ្ញាប្រតិកម្មដំបូង និងការមើលថែទាំសមរម្យដែលនឹងត្រូវអនុវត្ត។

លោកអ្នកអាចសួរសំណួរនៅពេលណាក៏បាន នៅក្នុងដំណើរការចាក់បញ្ចូលឈាម។

### តើមានជំរើសផ្សេងទៀតក្រៅពីការចាក់បញ្ចូលឈាមឬទេ?

ជំរើសផ្សេងទៀតក្រៅពីការចាក់បញ្ចូលឈាម កំពុងត្រូវបានគេបង្កើតឲ្យមានឡើងជាបន្តបន្ទាប់ ហើយត្រូវគេយកទៅប្រើនៅពេលណាដែលអាចធ្វើទៅបាន។ លោកអ្នកអាចសាកសួរវេជ្ជបណ្ឌិតរបស់លោកអ្នក អំពីជំរើសផ្សេងទៀតទាំងនេះ។ របៀបវះកាត់ដែលបានធ្វើឲ្យល្អប្រសើរឡើង ត្រូវបានគេប្រើដើម្បីកាត់បន្ថយចំនួននៃការហូរឈាម ហើយធ្វើឲ្យមានតិចបំផុតទៅលើសេចក្តីត្រូវការឈាម។ ទោះបីជាយ៉ាងណាក្តីសភាពគ្រោះថ្នាក់ពីការមិនបានចាក់បញ្ចូលឈាម នៅពេលដែលលោកអ្នកត្រូវការនោះ គឺវាធំជាងការចាក់បញ្ចូលឈាម។